# រឿងទី៥: ពិធីជប់លៀងចុងក្រោយបំផុត

**បទគម្ពីរ៖ ម៉ាថាយ២៦:២៦**

នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ងមកកាន់ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានអោយពួកសិស្ស ដោយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំ សុំយកពិសាចុះ»



ពិធីបុណ្យចម្លងដែលជាពិធីបុណ្យរបស់អ៊ីស្រាអែលបានខិតជិតចូលមកដល់។

ពិធីបុណ្យចម្លង គឺជាពិធីបុណ្យធ្វើឡើងដើម្បីរំលឹកពេលព្រះជាម្ចាស់ រំដោះប្រជារាស្ត្រអ៊ីស្រាអែលឱ្យរួចផុតពីជីវិតជាទាសករពីប្រទេសអេស៊ីប ឱ្យមានសេរីភាព។

ពិធីបុណ្យនេះ ជាពិធីបុណ្យដ៏ធំបំផុតមួយដែលត្រូវតែគោរពធ្វើជាដាច់ខាត ជាថ្ងៃដ៏មានអំណរសម្រាប់រាស្ត្រអ៊ីស្រាអែល។

ព្រះយេស៊ូទ្រង់បានជ្រាបរួចហើយ ថាពេលនេះជិតដល់ថ្ងៃទ្រង់យាងត្រឡប់ទៅនគរស្ថានសួគ៌វិញហើយ ក្រោយពីបំពេញកិច្ចការរបស់ទ្រង់នៅផែនដីនេះរួចអស់ហើយ។ ដូច្នេះហើយ ទើបព្រះយេស៊ូបានរៀបចំការបរិភោគអាហារជុំគ្នាជាមួយពួកសាវ័កទ្រង់យ៉ាងពិសេស មុនថ្ងៃនៃពិធីបុណ្យចម្លងមកដល់។

ពេលពួកសាវ័កទាំងអស់បានចូលមកអង្គុយនៅតុអាហារ ព្រះយេស៊ូបានចាប់ផ្ដើមលាងជើងពួកសាវ័កម្ដងម្នាក់ៗ។

ពួកសាវ័កទាំងអស់មានការភ្ញាក់ផ្អើលជាខ្លាំង។ ពួកសាវ័កបានសុំឱ្យព្រះយេស៊ូកុំធ្វើដូច្នេះ ប៉ុន្តែ ព្រះយេស៊ូនៅតែបន្តលាងជើងឱ្យពួកសាវ័កម្ដងម្នាក់ៗតាមលំដាប់លំដោយយ៉ាងស្ងាត់។ ធ្វើឱ្យពួកសាវ័កទាំងអស់មិនស្រួលក្នុងចិត្ត ប៉ុន្តែមិនដឹងត្រូវធ្វើយ៉ាងម៉េច។

ឥឡូវដល់វេន ពេត្រុសម្ដង។ ពេត្រុសបានទូលទៅព្រះយេស៊ូថា៖ «ព្រះអម្ចាស់អើយ តើវាមិនសមទេឬអី ដែលឱ្យទ្រង់មកលាងជើងដ៏គគ្រិចរបស់ទូលបង្គំជាអ្នកបម្រើរបស់ទ្រង់ដូច្នេះ? វាមិនសមទេព្រះអង្គ» ព្រះយេស៊ូបានមានបន្ទូលទៅគាត់ថា៖ «ប្រសិនបើខ្ញុំមិនលាងជើងអ្នកទេ អ្នកមិនអាចក្លាយជាសាវ័ករបស់ខ្ញុំបានឡើយ»

ពេលនោះ ទើបពេត្រុសបើកចិត្ត លោកមិនត្រឹមតែសូមឱ្យព្រះយេស៊ូលាងជើងប៉ុណ្ណោះទេ គឺសូមឱ្យលាងទាំងដៃ និងក្បាលរបស់គាត់ផង។

ក្រោយពីបានលាងជើងសាវ័កទាំងដប់ពីររួចអស់ហើយ ព្រះយេស៊ូក៏យាងមកអង្គុយនៅតុអាហាររួចមានបន្ទូលថា៖ «ចូរអ្នករាល់គ្នាលាងជើងអ្នកដទៃទៀត ដូចខ្ញុំបានលាងជើងឱ្យអ្នករាល់គ្នាចុះ ចូរប្រព្រឹត្តដាក់អ្នកដទៃ ដូចជាខ្ញុំបានប្រព្រឹត្តដាក់អ្នកចុះ» ពួកសាវ័កទាំងអស់ បានយកព្រះបន្ទូលរបស់ព្រះយេស៊ូមកចងចាំក្នុងជម្រៅដួងចិត្តរបស់ពួកគេ។ ។

ព្រះយេស៊ូបានយកនំប៉័ងមកកាន់ ហើយអធិស្ឋានអរព្រះគុណព្រះជាម្ចាស់ រួចទ្រង់បានកាច់នំប៉័ងនោះចែកដល់ពួកសាវ័ក

បន្ទាប់មក ទ្រង់យកពែងស្រាទំពាំងបាយជូរមក ហើយអធិស្ឋាន រួចចែកឱ្យដល់ពួកសាវ័ក ក្រោយពីបរិភោគអាហាររួចហើយ ព្រះយេស៊ូបានមានបន្ទូលទៅពួកសាវ័កថា៖ «ទោះបីថា ពេលនេះ ពួកអ្នករាល់គ្នាបានដើរតាមខ្ញុំក៏ពិតមែន ប៉ុន្តែ មិនយូរទេ ពួកអ្នកនឹងបោះបង់ខ្ញុំចោល ហើយបែកខ្ញែកគ្នាជាមិនខាន»។

ព្រះយេស៊ូក៏មានបន្ទូលទៀតថា៖ «ដល់ពេលដែលខ្ញុំត្រូវចាកចេញហើយ។ កន្លែងដែលខ្ញុំនឹងទៅនោះ ជាអ្នកកន្លែងដែលអ្នករាល់គ្នាមិនទាន់អាចទៅបាន។ ខ្ញុំនឹងទៅស្ថានសួគ៌ ដើម្បីរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា ហើយខ្ញុំនឹងត្រឡប់មកវិញម្ដងទៀត។

ព្រះយេស៊ូបានសន្យាជាមួយនិងពួកសាវ័ករបស់ទ្រង់ថា នឹងយាងមកជួបពួកគេម្ដងទៀត ទ្រង់បានធ្វើពិធីជប់លៀងចុងក្រោយនេះជាមួយគ្នា។

ពួកសិស្សទាំងអស់បានបន្តធ្វើការកាច់នំប៉័ង និងចែកស្រាទំពាំងបាយជូរនេះ រហូតមកដល់សព្វថ្ងៃ ដើម្បីជាការរំលឹក។

ពិធីនេះគេហៅថា "ពិធីលៀងព្រះអម្ចាស់"។ តាមរយៈពិធីលៀងព្រះអម្ចាស់នេះ បានរំលឹកយើងឱ្យនឹកចាំពីការសុគតរបស់ព្រះយេស៊ូ ដោយសារតែអំពើបាបយើង ធ្វើឱ្យយើងមានចិត្តអរព្រះគុណព្រះយេស៊ូដែលបានជួយសង្គ្រោះយើងពីអំពើបាប។



## សកម្មភាពទី១ សូមឆ្លើយនឹងសំណួរខាងក្រោម។



ក. តើព្រះយេស៊ូបានលាងជើងឱ្យអ្នកណា នៅក្នុងពិធីជប់លៀងចុងក្រោយនេះ?

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

ខ. តើព្រះយេស៊ូបានបរិភោគអ្វីជាមួយពួកសាវ័ក នៅក្នុងពិធីជប់លៀងចុងក្រោយនេះ?

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

គ. សូមអានព្រះគម្ពីរម៉ាថាយ២៦:១៧-២៩ រួចឆ្លើយនិងសំណួរ។ តើព្រះយេស៊ូមានព្រះបន្ទូលប្រៀបប្រដូចនំប៉័ងនិងស្រាទំពាំងបាយជូរនឹងអ្វី?

- - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - - -

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(ម៉ាថាយ២៦:២៦)

**នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ងមកកាន់ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានអោយពួកសិស្ស ដោយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំ សុំយកពិសាចុះ»**

**សកម្មភាពទី២** សូមគូររូបជើងដ៏ស្អាតរបស់ខ្លួន។



